# មន្ទីរកសិកម្មខេត្តកណ្ដាល

## ទ្រីប




អាស័យដ្ឋានទំនាក់ទំនងៈផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)



ឧបត្ថម្ភដោយៈ អង្គការវីវីអូប៊ី VVOB

education for development

ឆ្នាំ ២០១០


# ទ្រីប

## ១.លក្ខណៈរូបសាស្ត្រ

ទ្រីបជាសត្វល្អិតដែលបំផ្លាញដំណាំស្រូវ ជាពិសេសនៅក្នុងដំណាក់កាលសំណាប។ វាបំផ្លាញនៅលើថ្នាល និងស្រូវពង្រួសដែលមានការរាំងស្ងួត។ ដំណាក់កាលស្រូវបែកគុម្ព ទៅបែកគុម្ពពេញទំហឹងមានការបំផ្លាញខ្លះៗតែប៉ុណ្ណោះ។ សត្វល្អិតប្រភេទនេះមានវត្តមាននៅគ្រប់បរិស្ថានដំណាំស្រូវទាំងអស់។ នៅតំបន់ត្រូពិច ទ្រីបមានច្រើនក្រៃលែងក្នុងរដូវរាំងស្ងួត ពី ខែ កក្កដា ដល់ខែ កញ្ញា និងពីខែ មករា ដល់ខែ មិនា។ នៅពេលមានអាកាសធាតុអំណោយផលវាចាប់ផ្ដើមធ្វើដំណើរ ហើយទៅសំងំនៅគុម្ពស្មៅក្នុងកំឡុងពេលរដូវត្រជាក់។

ទ្រីបមានដងខ្លួនឆ្មាស្ដើង ពណ៌ត្នោតចាស់ ហើយវែងមានបណ្ដោយប្រវែងពី ១មីលីម៉ែត្រ ទៅ ២មីលីម៉ែត្រ ហើយមានអង់តែនពី ៥ ទៅ ៨ កង់។ ទ្រីបមានពីរប្រភេទៈ ប្រភេទមានស្លាប និងប្រភេទគ្មានស្លាប។ ទ្រីបដែលមានស្លាប ស្លាបវាទាំងគូរនោះមានរាងទ្រវែងតូច ហើយមានរោមវែងនៅគែមជុំវិញ។

ពងវាមានសណ្ឋានដូចៗគ្នា ហើយជំរុះនៅក្នុងស្នាមប្រេះនៃជាលិការបស់ស្លឹក ដោយប្រដាប់បញ្ចេញពងរបស់ទ្រីបញី រីឯប្រដាប់បញ្ចេញពងនោះវិញមានសណ្ឋានដូចមុខរណារ។ ពងវាតូចមានបណ្ដោយ 0,២៥មីលីម៉ែត្រ និងទទឹង 0,១មីលីម៉ែត្រ ហើយមានលក្ខណៈស្រអាប់នៅពេលដែលទើបពងថ្មីៗ ប៉ុន្តែប្រែក្លាយជាពណ៌លឿងព្រលែតវិញនៅពេលវាជិតញាស់។ កូនទ្រីបដែលទើបញាស់ថ្មីៗគ្មានពណ៌ទេ។

បន្ទាប់ពីញាស់បានមួយរយៈ កូនទើបញាស់ស្ថិតនៅមួយកន្លែង គឺវាមិនទៅណាទេ ក្រោយមកក៏វារបន្តិចម្ដងៗទៅរកស៊ីជាលិកាទន់ៗនៃស្លឹកខ្ចីៗដែលពុំទាន់រលារនៅឡើយ គឺនៅក្នុងរមូរនៃស្លឹក ប៉ុន្តែនៅជិតគែមស្លឹកនោះតែម្ដង នៅត្រង់មុំក្រោមស្លឹក និងនៅក្នុងកួរស្រូវកំពុងលូតលាស់។ ជីវិតកូនទើបញាស់ និងដឹកឌឿប្រព្រឹត្តទៅនៅក្នុងជាលិកាទាំងនោះ រីឯទ្រីបពេញវ័យ រកស៊ីចិញ្ចឹមជីវិតរបស់វា នៅក្នុងជាលិកាទាំងនោះដែរតាំងពីទើបញាស់មកម្ល៉េះ។ មេចំណាស់មានរាងតូចៗ ហើយទន់។





## ២.វដ្ដជីវិត

ទ្រីបជាកក្កាចង្រៃបំផុតក្នុងរដូវរាំងស្ងួត។ វារុករានដំណាំស្រូវនៅកំឡុងពេលដំណាក់កាលសំណាប ឬពីរសប្ដាហ៍បន្ទាប់